ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៣៧/១៣-បូវឃើរ ហ្គាមេន ហ្វេកធើរី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **អាំង អេងថុង**

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន បូវឃើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភើនី លីមីធីត**
អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០៨៨ ៦៥ ៣៨ ៧៧៧ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ ៖

១- លោក Liu Zheng Jun Admin
២- លោក Doung Kim Heng បកប្រែ

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២ ៖

១- លោក Liu Zheng Jun Admin
២- លោក Doung Kim Heng បកប្រែ

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **-សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ**
**-សហជីពស្មារតីកម្មករខ្មែរ នៃក្រុមហ៊ុន បូវឃើរ ហ្គាមេន**

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល

ទូរស័ព្ទ ៖ ០១២ ៥៣ ៥៩ ៥៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ ៖

| | |
|---|---|
| ១- លោក សួស សុខា | អគ្គលេខាធិការរងសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ |
| ២- លោក មុំ សុភ័ស្ត | មន្ត្រីសម្របសម្រួលសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ |
| ៣- កញ្ញា ស៊ិន ហោ | ប្រធានសហជីពស្មារតីកម្មករខ្មែរប្រចាំក្រុមហ៊ុន បូវយើរ |
| ៤- កញ្ញា ផន បូរី | អនុប្រធានសហជីពស្មារតីកម្មករខ្មែរប្រចាំក្រុមហ៊ុន បូវយើរ |
| ៥- កញ្ញា ជ័រ ស្រីម៉ាច | លេខាធិការសហជីពស្មារតីកម្មករខ្មែរប្រចាំក្រុមហ៊ុន បូវយើរ |
| ៦- កញ្ញា ពៅ សុខវី | ទីប្រឹក្សាសហជីពស្មារតីកម្មករខ្មែរប្រចាំក្រុមហ៊ុន បូវយើរ |

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី២ ៖ អវត្តមាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ភាគីកម្មករទាមទារឱ្យក្រុមហ៊ុនទទួលយកប្រធានក្រុមដេរ ឈ្មោះ ពៅ សុខវី ចូលធ្វើការវិញជាធម្មតា។ ភាគីក្រុមហ៊ុនមិនឯកភាពទទួលយកប្រធានក្រុម ពៅ សុខវី ចូលធ្វើការវិញទេ ពីព្រោះ គាត់ពុំមានសមត្ថភាពគ្រប់គ្រាន់ដឹកនាំក្រុមការងារ។ ដោយឡែកប្រាក់បញ្ចប់កិច្ចសន្យាការងារ ក្រុមហ៊ុននឹងទូទាត់តាមច្បាប់ស្ដីពីការងារជូន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ១៩៥ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីអំពីការមិនសះជា លេខ ៤៩៧/១៣ កប/កណ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖**

- លើកទី១ ៖ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៣ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ) ។
- លើកទី២ ៖ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៣ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានដំណើរការផ្សះផ្សាវិវាទការងាររួមចំនួន ០១ ចំណុច ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០១ ចំណុច លើការទាមទារចំនួន ០១ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៣ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៤៩៧ កប/កណ ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០១៣។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការលើកទី ១ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១៣ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក និងមកសវនាការលើកទី ២ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣។ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ ដែលជាកាលបរិច្ឆេទសវនាការលើកទី ២ ភាគីនិយោជកបានចូលរួមសវនាការ ប៉ុន្តែ ភាគីកម្មករនិយោជិតមិនមានវត្តមានទេ។ ភាគីនិយោជកអះអាងថា ភាគីកម្មករនិយោជិតបានកំពុងធ្វើកូដកម្មទាមទារឱ្យប្រធានក្រុម ពៅ សុខវី ចូលធ្វើការវិញ ចាប់តាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ ដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០៣២/១៣ កបអ. ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ បញ្ជាឱ្យផ្អាកជាបន្ទាន់ការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) រហូតដល់នីតិវិធីអាជ្ញាកណ្តាល ត្រូវបានបញ្ចប់ សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ តទៅ តាមវេនរបស់ខ្លួន លើកលែងតែឈ្មោះ ពៅ សុខវី។ កូដករបានត្រលប់ចូលធ្វើការវិញតាមការបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣។

ភាគីទាំងពីរបានឯកភាពពន្យារការចេញសេចក្តីបង្គាប់នេះ ពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៣។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ របស់នាយកក្រុមហ៊ុន បូរយើរ ហ្គាមេន ផ្ទេរសិទ្ធិជូនលោក លីវ ជីងជីន ។

២- វិញ្ញាបនប័ត្របញ្ជាក់បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខ ៦២៦៨ ពណ.ចបព ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១២ របស់ក្រុមហ៊ុន បូរយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត។

៣- ប័ណ្ណប៉ាតង់ឆ្នាំ២០១២ លេខ DLT.037395.2012 ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ក្រុមហ៊ុន បូរយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត។

៤- កិច្ចសន្យាសាកល្បងរបស់ ពៅ សុខរី ។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន បូរយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភេនី លីមីធីត ដែលបានឃើញ និងបញ្ជាក់ថា ត្រឹមត្រូវ ដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាលលេខ ៣៨២ កបវ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣។

៦- លិខិតលេខ ៧៧៥ កប/អក/វក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ របស់ប្រធាននាយកដ្ឋានវិវាទការងារ ជម្រាបមក អ្នកស្រី ស្រ៊ិន ហោ ស្តីពីការចុះបញ្ជិកាសហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន បូរយើរ ហ្គាមេន។

៧- របាយការណ៍ស្តីពីវិវាទការងារនៅក្រុមហ៊ុន បូរយើរ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣។

៨- តារាងផ្តល់ដំណឹងប័ណ្ណកាម៉ុង។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

- បង្កាន់ដៃទទួលសំណុំរឿងរបស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលពីសហជីពស្មារតីកម្មករខ្មែរ (បូរយើ) ស្តីពីសុំចុះបញ្ជិកា ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន បូរយើរ ហ្គាមេន ហ្វេកធើរី លេខ ៤៩៧ /១៣ កប/កណ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន បូរយើរ ហ្គាមេន ហ្វេកធើរី ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៦៨១ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៦៨២ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែ

កក្កដា ឆ្នាំ២០១៣។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៧២៤ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៧២៥ កប/អក/វក/លកអ. ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣។

៥- សេចក្តីបញ្ជាក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៣២/១៣ កបអ. ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភើនី លីមីធីត គឺជារោងចក្រកាត់ដេរសំលៀកបំពាក់។ ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតប្រមាណចំនួន ៧០០នាក់។
- ស្រ៊ិន ហោ, វ៉ង់ សុភក្រ័, ញ៉ឹម ធារី, ផន បូរី និងពៅ សុខវី ជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ នៅថ្ងៃសវនាការថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣ ពៅ សុខវី និង ស្រ៊ិន ហោ មានវត្តមាននៅក្នុងសវនាការ ហើយពួកគាត់ត្រូវបានអម ដោយឈ្មោះ សួស សុខា ដែលជាអគ្គលេខាធិការរង និង មុំ សុភ័ស្ត ដែលជាមន្ត្រីសម្របសម្រួលរបស់សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ និង កម្មការិនី ផន បូរី និងកម្មការិនី ជ័រ ស្រីម៉ាច។ សហជីពស្មារតីកម្មករខ្មែរប្រចាំក្រុមហ៊ុន បូវយើរ ហ្គាមេន ហ្វេកធើរី (ខេមបូឌា) ខមភើនី លីមីធីត មិនទាន់ទទួលបានវិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ចំណុចវិវាទ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកប្រធានក្រុមដេរឈ្មោះ ពៅ សុខវី ចូលធ្វើការវិញ***

- ភាគីកម្មករនិយោជិត និងភាគីនិយោជកបានឯកភាពគ្នាថា ៖
    - កម្មការិនី ពៅ សុខវី ចូលធ្វើការដំបូងនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ តាមរយៈកិច្ចសន្យាការងារសាកល្បងរយៈពេល ២ ខែ។ គាត់មានតួនាទីជាប្រធានក្រុមដេរ និងទទួលបានប្រាក់ឈ្នួលសរុបប្រចាំខែចំនួន ១៥០ ដុល្លារអាមេរិក។
    - និយោជកបញ្ឈប់កម្មការិនី ពៅ សុខវី ដោយមិនមានការជូនដំណឹងមុន នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៣។
    - មកដល់ថ្ងៃសវនាការលើកទី ១ នេះ មានតែ ពៅ សុខវី ម្នាក់គត់ ដែលត្រូវនិយោជកបញ្ឈប់ពីការងារ។ សហជីពស្មារតីកម្មករខ្មែរមានទីប្រឹក្សាចំនួន១២នាក់។ និយោជកបានផ្ទេរអនុប្រធាននិងលេខាធិការសហជីពទៅផ្នែកផ្សេង ដោយនិយោជកអះអាងថា ពួកគាត់បំពេញការងារមិនបានល្អ។

- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារ គឺដោយសារ ៖
  - ការបញ្ឈប់កម្មការិនី ពៅ សុខវី ពីការងារ ពាក់ព័ន្ធនឹងការរើសអើងសហជីព ដោយហេតុថា គាត់ជាទីប្រឹក្សាសហជីពស្មារតីកម្មករខ្មែរ ។
  - គាត់ធ្វើការងារបានល្អប្រសើរនៅក្នុងរយៈពេលសាកល្បងការងារនេះ ហើយនិយោជកក៏មិនបានជូនដំណឹងគាត់អំពីការបញ្ឈប់នេះដែរ ។
- ភាគីនិយោជកលើកឡើងថា ការបញ្ឈប់កម្មការិនី ពៅ សុខវី ពីការងារ គឺផ្អែកលើកំហុសដែលគាត់បានដេរខោខុសចំនួន ៦០០ នៅក្នុងអំឡុងពេលកិច្ចសន្យាការងារសាកល្បងរបស់គាត់ ។ ភាគីនិយោជកបញ្ជាក់បន្ថែមទៀតថា និយោជកអាចបញ្ឈប់គាត់ភ្លាមៗបាន ប្រសិនបើគាត់មានកំហុស ដោយសារគាត់ធ្វើការក្រោមកិច្ចសន្យាការងារសាកល្បង ។
- ភាគីកម្មករនិយោជិតអះអាងថា កម្មការិនី ពៅ សុខវី ធ្វើការដេរខោតាមការចាត់ចែងរបស់ប្រធានផ្នែក ។ ដូចនេះ វាមិនមែនជាកំហុសរបស់គាត់ទេ ។
- ភាគីនិយោកជកអះអាងថា ការអនុវត្តរបស់និយោជក គឺមុននឹងចាប់ផ្តើមដេរខោ និយោជកនឹងផ្តល់តារាងផ្តល់ដំណឹងប័ណ្ណកាម៉ុងទៅប្រធានផ្នែក ។ បន្ទាប់មក ប្រធានផ្នែកនឹងប្រាប់ ហើយឱ្យតារាងនេះទៅប្រធានក្រុមដេរឱ្យចាត់ចែងដេរតាមពុម្ព ដែលមាននៅក្នុងតារាង ។ នៅក្នុងករណីនេះ ប្រធានក្រុម ពៅ សុខវី មិនដេរតាមប្រធានផ្នែកទេ ។
- ភាគីកម្មករនិយោជិតលើកឡើងថា ប្រធានផ្នែកមិនឱ្យតារាងផ្តល់ដំណឹងប័ណ្ណកាម៉ុងទៅប្រធានក្រុមទេ ។ ប្រធានផ្នែក គឺជាអ្នកវាស់ពុម្ពខោ ឱ្យកម្មករនិយោជិតដេរតាម ។ នៅពេលដេរខោទាំង ៦០០ នោះ ប្រធានក្រុម ពៅ សុខវី ដេរតាមតែខ្នាតនៅលើតុ ដែលវាស់ដោយប្រធានផ្នែកប៉ុណ្ណោះ ។ ប្រធានផ្នែកមិនដឹងថាខោទាំង ៦០០ នោះដេរខុសដែរ ទើបតែនៅថ្ងៃចេញផលិតផល ប្រធានផ្នែកយកខោ ស៊េរី XL ពីរកាតុងមកឱ្យគាត់ធ្វើការកែតម្រូវ ។ កម្មការិនី ពៅ សុខវី មិនចាំថា នៅក្នុងកាតុងចំនួនពីរនោះ មានខោចំនួនប៉ុន្មានទេ ។
- ភាគីនិយោជកអះអាងថា ខ្នាតនៅលើតុ គឺប្រធានក្រុមជាអ្នកវាស់ និងកាត់ខោដោយខ្លួនឯង ទៅតាមតារាងផ្តល់ដំណឹងប័ណ្ណកាម៉ុង ។ ស្លាយខោខាងលើ គឺជាស្លាយចាស់ទេ ។ ដូចនេះ វាជាកំហុសរបស់គាត់ នៅពេលដែលគាត់ដេរខុស ។
- ភាគីកម្មករនិយោជិតនៅតែទទូចថា ការបញ្ឈប់ប្រធានក្រុម ពៅ សុខវី ពីការងារ គឺដោយសារសមាជិកភាពរបស់គាត់នៅក្នុងសហជីព ។
- នៅក្នុងសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសួរភាគីកម្មករនិយោជិតអំពីព័ត៌មានសហជីពស្មារតីកម្មករខ្មែរ ដូចជា កាលបរិច្ឆេទនៃការបោះឆ្នោតសហជីព, កាលបរិច្ឆេទនៃជូនដំណឹងអំពីសមាសភាពអ្នកចូលរួមបង្កើតសហជីពជាដើម ប៉ុន្តែ ភាគីកម្មករនិយោជកមិនចាំអំពីព័ត៌មានទាំងនេះទេ ហើយបានស្នើសុំក្រុមប្រឹក្សាអាជ្ញាកណ្តាលដាក់ព័ត៌មានទាំងនេះក្រោយសវនាការ ដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលកំណត់ កាល

THE ARBITRATION COUNCIL

បរិច្ឆេទដាក់ភស្តុតាង ត្រឹមថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣។ នៅក្នុងករណីនេះ ដោយសារភាគីទាំងពីរមានវិវាទទៅលើអង្គហេតុថា តើប្រធានផ្នែក ឬប្រធានក្រុមជា អ្នកវាស់ខ្នាតខោឱ្យកម្មករ និយោជិតដេរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃសវនាការលើកទី ២ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ ដើម្បីហៅប្រធានក្រុមដទៃទៀត និងប្រធានផ្នែកមកបំភ្លឺលើករណីនេះ។

- មកដល់ត្រឹមថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ ភាគីកម្មករនិយោជិតមិនបានដាក់ឯកសារទាក់ទងនឹងព័ត៌មានសហជីពមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។
- នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ ភាគីនិយោជក, ប្រធានក្រុមដទៃទៀត និងប្រធានផ្នែក បានមកចូលរួមសវនាការលើកទី ២ ប៉ុន្តែភាគីកម្មករនិយោជិតមិនបានមកចូលរួមទេ។ ភាគីនិយោជកអះអាងថា ភាគីកម្មករនិយោជិតបានធ្វើកូដកម្មទាមទារឱ្យនិយោជកទទួលយកប្រធានក្រុម ពៅ សុខវី ចូលធ្វើការវិញ តាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ រហូតមកដល់ថ្ងៃសវនាការលើកទី ២ នេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០៣២/១៣ កបអ. ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ បញ្ជាឱ្យកូដករផ្អាកជាបន្ទាន់ការធ្វើកូដកម្មហើយកូដករទាំងអស់ ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០១៣ តទៅ តាមវេនរបស់ខ្លួន លើកលែងតែឈ្មោះ ពៅ សុខវី។ កូដករបានត្រលប់ចូលធ្វើការវិញ តាមការបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន រហូតដល់ថ្ងៃចេញសេចក្តីបង្គាប់។

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកប្រធានក្រុមដេរឈ្មោះ ពៅ សុខវី ចូលធ្វើការវិញ**

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកប្រធានក្រុម ពៅ សុខវី ចូលធ្វើការវិញ ដោយសារការបញ្ឈប់គាត់ពីការងារពាក់ព័ន្ធនឹងការរើសអើងសហជីព។ ភាគីនិយោជកលើកឡើងថា ការបញ្ឈប់ប្រធានក្រុម ពៅ សុខវី ពីការងារ គឺផ្អែកលើកំហុសដែលគាត់ដេរខោខុសចំនួន ៦០០ នៅក្នុងអំឡុងពេលកិច្ចសន្យាការងារសាកល្បងរបស់គាត់។ ភាគីនិយោជកបញ្ជាក់បន្ថែមទៀតថា និយោជកអាចបញ្ឈប់គាត់ភ្លាមៗបាន ប្រសិនបើគាត់មានកំហុស ដោយសារគាត់ធ្វើការក្រោមកិច្ចសន្យាការងារសាកល្បង។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា ទី១-តើការបញ្ចប់កិច្ចសន្យាការងារសាកល្បងនេះ មានពាក់ព័ន្ធនឹងការរើសអើងសហជីព ដែរឬទេ? និងទី២-តើការបញ្ចប់កិច្ចសន្យាការងារសាកល្បងនេះធ្វើឡើងត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ដែរឬទេ?

**(១) ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើ ការបញ្ចប់កិច្ចសន្យាការងារសាកល្បងរបស់ កម្មការិនី ពៅ សុខវី ពាក់ព័ន្ធនឹងការរើសអើងសហជីពដែរ ឬទេ?**

មាត្រា ១២ នៃច្បាប់ស្តីពីការងារចែងថា *"....គ្មាននិយោជកណាម្នាក់ អាចយកបញ្ហា... ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬ ការធ្វើសកម្មភាពក្នុងសហជីពដើម្បីជាលេសធ្វើសេចក្តីសំរេចអំពី:... វិន័យ ឬការផ្តាច់*

*កិច្ចសន្យាការងារ...”*។

មាត្រា ២៧៩ នៃច្បាប់ស្តីពីការងារចែងថា *“ត្រូវហាមឃាត់ចំពោះនិយោជកគ្រប់រូប មិនឱ្យយកការចូលរួមជាសមាជិករបស់សហជីព ឬការចូលរួមក្នុងសកម្មភាពរបស់សហជីពនៃកម្មករនិយោជិត ដើម្បីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសឱ្យចូលធ្វើការងារ ការដឹកនាំ និងការបែងចែកការងារ ការតំឡើងថ្នាក់ ការផ្តល់ប្រាក់ឈ្នួល និងការផ្តល់ផលប្រយោជន៍ វិធានការដាក់វិន័យ និងការបណ្តេញចេញ”* ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតបានលើកឡើងថា ការបញ្ឈប់ប្រធានក្រុម ពៅ សុខវី ពីការងារត្រូវបានធ្វើឡើងដោយពាក់ព័ន្ធនឹងការរើសអើងសហជីព ដោយសារគាត់ជាទីប្រឹក្សាសហជីពស្មារតីកម្មករខ្មែរ។ ភាគីនិយោជកបានជំទាស់នឹងការចោទប្រកាន់ ដោយអះអាងថា ការបញ្ឈប់ ពៅ សុខវី មិនពាក់ព័ន្ធនឹងការរើសអើងសហជីពទេ ពីព្រោះថា គាត់បានដេរខោខុស ចំនួន ៦០០ ខោ ហើយនិយោជកអាចបញ្ឈប់គាត់បានភ្លាមៗ ដោយសារគាត់ធ្វើការក្រោមកិច្ចសន្យាការងារសាកល្បង។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការបកស្រាយយ៉ាងស៊ីសង្វាក់គ្នាថា *“ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថា ភាគីដែលធ្វើការចោទប្រកាន់មានបន្ទុកភស្តុតាង ក្នុងការបង្ហាញមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីគាំទ្រការចោទប្រកាន់ទាំងនេះ”*។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៤៨/០៧-ជ៉ាយហ៊ី, លេខ ៣៤/១១-លីម ឡាញ ហេតុផលចំណុចវិវាទទី៧ និង១៥៥/១១-យីងដុង ហេតុផលចំណុចវិវាទទី១)* ។

ទាក់ទងនឹងភស្តុតាងនៃការរើសអើងសហជីព ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើការឆ្លើយបំភ្លឺនៅក្នុងសវនាការ និងធ្វើការពិនិត្យទៅលើភស្តុតាង ដែលពាក់ព័ន្ធទៅនឹងសំណុំរឿងដើម្បីកំណត់ថា មានការរើសអើងសហជីពកើតមានឡើងដែរ ឬទេ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ១៤៨/០៧-ជ៉ាយហ៊ី*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ។

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតបានលើកឡើងថា ប្រធានក្រុម ពៅ សុខវី ដេរខោតាមពុម្ពដែលវាស់ដោយប្រធានផ្នែកប៉ុណ្ណោះ។ ដូចនេះ គាត់មិនបានប្រព្រឹត្តិកំហុសទេ។ ភាគីនិយោជកអះអាងថា ប្រធានក្រុម គឺជាអ្នកវាស់ពុម្ពខោ និងដេរខោដោយខ្លួនឯង។ ដោយសារភាគីទាំងពីរមានវិវាទទៅលើអង្គហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់កាលបរិច្ឆេទសវនាការលើកទី ២ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ ដើម្បីហៅប្រធានក្រុមផ្សេងៗទៀត និងប្រធានផ្នែកមកឆ្លើយបំភ្លឺលើករណីនេះ។

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ ដែលជាកាលបរិច្ឆេទសវនាការលើកទី ២ ភាគីនិយោជក, ប្រធានក្រុមផ្សេងៗទៀត និងប្រធានផ្នែក បានមកចូលរួមសវនាការ ប៉ុន្តែភាគីកម្មករនិយោជិតមិនមានវត្តមាននៅក្នុងសវនាការទេ។ ភាគីនិយោជកអះអាងថា ភាគីកម្មករនិយោជិតបានកំពុងធ្វើកូដកម្មទាមទារឱ្យនិយោជកទទួលយកប្រធានក្រុម ពៅ សុខវី ចូលធ្វើការវិញ ចាប់តាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ រហូតមកដល់ថ្ងៃសវនាការនេះ។ នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការ ដើម្បីសួរបញ្ជាក់ប្រធានក្រុមផ្សេងៗទៀត និងប្រធានផ្នែកអំពីការអនុវត្តរបស់និយោជកថា តើប្រធានក្រុម ឬប្រធានផ្នែកដែលទទួល

ខុសត្រូវលើការការវាស់ពុម្ពខោ ឱ្យកម្មករនិយោជិតដេរ។ ដោយសារភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការលើកទី ២ តាមការអញ្ជើញ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតបានបោះបង់ចោលឱកាសក្នុងការការពារ បន្តការអះអាងទាក់ទងនឹងការចោទប្រកាន់និយោជកថា បានបញ្ឈប់គាត់ ដោយមានការរើសអើងសហជីព និងការពារការទាមទាររបស់ខ្លួន តាមរយៈការសាកសួរសាក្សី ដែលពាក់ព័ន្ធបន្ថែមនៅថ្ងៃសវនាការលើកទីពីរ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានបំពេញបន្ទុកភស្តុតាងក្នុងការបង្ហាញជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ការបញ្ឈប់ប្រធានក្រុម ពៅ សុខវី មានការពាក់ព័ន្ធនឹងការរើសអើងសហជីពឡើយ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលច្រានចោលនូវការលើកឡើងរបស់ភាគីកម្មករនិយោជិតថា ការបញ្ឈប់ប្រធានក្រុមដេរ ពៅ សុខវី ពីការងារនៅក្នុងអំឡុងពេលកិច្ចសន្យាការងារសាកល្បង មានការពាក់ព័ន្ធនឹងការរើសអើងសហជីព។

**(២) ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការបញ្ចប់កិច្ចសន្យាការងារសាកល្បងរបស់កម្មការិនី ពៅ សុខវី ធ្វើឡើងត្រឹមត្រូវតាមច្បាប់ស្តីពីការងារដែរឬទេ?**

យោងតាមអង្គហេតុ កម្មការិនី ពៅ សុខវី មានកិច្ចសន្យាការងារសាកល្បងរយៈពេល ២ ខែ។

មាត្រា ៧៣ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីការងារចែងថា *"ភាគីទាំងឡាយមិនបាច់គោរពកាតព្វកិច្ចអោយដំណឹងមុនក្នុងករណីដូចតទៅ ៖*

*- ក្នុងករណីចូលធ្វើការសាកល្បង ឬកម្មសិក្សាដែលមានចែងក្នុងកិច្ចសន្យា ។*

*- ក្នុងករណីមានកំហុសធ្ងន់នៃភាគីណាមួយ ។*

*- ក្នុងករណីប្រធានស័ក្តិ ដែលភាគីម្ខាងមិនអាចគោរពកិច្ចសន្យារហូតតទៅបាន ។"*

នៅក្នុងសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា និយោជកពុំចាំបាច់ផ្តល់ហេតុផលសម្រាប់បណ្តេញចេញពីការងារ នៅក្នុងកំឡុងពេលសាកល្បងការងារនោះទេ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ២៧/០៣-ស្តែនដឺត ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ និងលេខ ១២/១០ - ប៊ួសសេម សេនជូរី ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី ២)* ។

ក្រុមអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ។

យោងតាមមាត្រា ៧៣ និងសេចក្តីសម្រេចមុនៗរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលខាងលើ និយោជកមិនមានកាតព្វកិច្ចជូនដំណឹងមុនការបញ្ចប់កិច្ចសន្យា និងពុំចាំបាច់ផ្តល់ហេតុផលក្នុងបញ្ឈប់កម្មករនិយោជិត ក្នុងរយៈកិច្ចសន្យាការងារសាកល្បងឡើយ។

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកទទួលយកប្រធានក្រុមដេរឈ្មោះ ពៅ សុខវី ចូលធ្វើការវិញ។

THE ARBITRATION COUNCIL

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ ៖**

បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកទទួលយកប្រធានក្រុមដេរឈ្មោះ ពៅ សុខវី ចូលធ្វើការវិញ ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុំ សុធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖ ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **អាំង អេងថុង**

ហត្ថលេខា ៖ ------------------------------